2016-
មេសា

ភាសា

## សម្រាប់ជនបរទេសដែលត្រូវបានចុះបញ្ជីជានិវេសនជននៅប្រទេសជប៉ុន៖
## ព័ត៌មានទាក់ទងនឹងលេខឯកត្តជន (លេខរបស់ខ្ញុំ)

ចាប់ពីខែមករា ឆ្នាំ2016 នេះតទៅ លេខសន្តិសុខសង្គម និងសារពើពន្ធ (ឬហៅថាលេខឯកត្តជន ឬ "លេខរបស់ខ្ញុំ") ត្រូវបានប្រើប្រាស់សម្រាប់ការឆ្លើយតបចំពោះសន្តិសុខសង្គម ពន្ធដារ និងគ្រោះមហន្តរាយ។

### 1. តើលេខឯកត្តជនគឺជាអ្វី?

- លេខឯកត្តជន (ឬហៅម្យ៉ាងទៀតថា "លេខរបស់ខ្ញុំ") គឺជាលេខ 12 ខ្ទង់សម្រាប់បុគ្គលម្នាក់ៗដែលរស់នៅប្រទេសជប៉ុនក្រោមប្រព័ន្ធលេខសន្តិសុខសង្គម និងសារពើពន្ធ។ លេខនេះត្រូវបានប្រើប្រាស់សម្រាប់ការឆ្លើយតបចំពោះសន្តិសុខសង្គម ពន្ធដារ និងគ្រោះមហន្តរាយ។ ប្រព័ន្ធនេះដើរតួជាហេដ្ឋារចនាសម្ព័ន្ធសង្គម ដើម្បីបង្កើនតម្លាភាពផ្នែករដ្ឋបាល ផ្តល់ភាពងាយស្រួលបន្ថែមទៀតដល់សាធារណជន និងបង្កើតសង្គមដ៏ត្រឹមត្រូវ និងយុត្តិធម៌មួយ។
- ជនបរទេសដែលត្រូវបានចុះបញ្ជីជានិវេសនជននៅប្រទេសជប៉ុន (និវេសនជនរយៈពេលមធ្យម និវេសនជនអចិន្ត្រៃយ៍ពិសេស។ល។) ក៏នឹងទទួលបានលេខឯកត្តជនរបស់ពួកគេផងដែរ។

### 2. ការជូនដំណឹងពីលេខឯកត្តជនរបស់អ្នក

- បើអ្នកត្រូវបានចុះបញ្ជីជានិវេសនជននៅប្រទេសជប៉ុន លេខឯកត្តជនរបស់អ្នកត្រូវបានបោះពុម្ពនៅលើប័ណ្ណជូនដំណឹងដែលអ្នកទទួលពីការិយាល័យក្រុងតាមអាសយដ្ឋានចុះបញ្ជីរបស់អ្នក។ (ប័ណ្ណជូនដំណឹងនោះនឹងមិនអស់សុពលភាពប្រើប្រាស់ឡើយ។ សូមកុំបោះចោលប័ណ្ណជូនដំណឹងរបស់អ្នក។ អ្នកត្រូវរក្សាវាទុកឲ្យបានល្អ។)
- ជនបរទេសដែលចូលទៅកាន់ប្រទេសជប៉ុនក្នុងស្ថានភាពជានិវេសនជនរយៈពេលមធ្យម និងវែង នឹងទទួលបានលេខឯកត្តជនរបស់ពួកគេនៅពេលចុះបញ្ជីនិវេសនជន។

### 3. ពេលណាដែលត្រូវប្រើលេខឯកត្តជន

- អ្នកនឹងបង្ហាញលេខឯកត្តជនរបស់អ្នកទៅកាន់ការិយាល័យពន្ធដារសម្រាប់ការអនុវត្តនីតិវិធីសារពើពន្ធ ដូចជានៅពេលធ្វើប្រតិវេទន៍ពន្ធឬប្រកាសពន្ធ សម្រាប់ឆ្នាំ2016 និងឆ្នាំក្រោយៗទៀត។
- អ្នកនឹងបង្ហាញលេខឯកត្តជនរបស់អ្នកទៅកាន់និយោជករបស់អ្នកសម្រាប់ប្រើប្រាស់ក្នុងការអនុវត្តនីតិវិធីសារពើពន្ធ និងសន្តិសុខសង្គម។
- អ្នកនឹងបង្ហាញលេខឯកត្តជនរបស់អ្នកទៅកាន់ក្រុមហ៊ុនមូលប័ត្រ និងក្រុមហ៊ុនធានារ៉ាប់រងសម្រាប់ការអនុវត្តនីតិវិធីសារពើពន្ធ។
- អ្នកនឹងបង្ហាញលេខឯកត្តជនរបស់អ្នកទៅកាន់ការិយាល័យក្រុងរបស់អ្នក ដើម្បីទទួលបានអត្ថប្រយោជន៍សុខុមាលភាព និងសម្រាប់ការអនុវត្តនីតិវិធីនានាក្រោមកម្មវិធីធានារ៉ាប់រងសុខភាពជាតិ និងធានារ៉ាប់រងថែទាំដោយគិលានុបដ្ឋាក។
- អ្នកនឹងបង្ហាញលេខឯកត្តជនរបស់អ្នកទៅកាន់ធនាគារ ឬប្រៃសណីយ៍នៅពេលផ្ញើទៅកាន់ ឬទទួលប្រាក់ពីប្រទេសផ្សេងៗ។

សម្គាល់៖ ក្នុងនីតិវិធីដូចបានរៀបរាប់ខាងលើ ស្ថាប័នដែលទទួលខុសត្រូវលើលេខឯកត្តជនរបស់អ្នកនឹងបង្ការមិនឲ្យមានការក្លែងអត្តសញ្ញាណ តាមរយៈការបញ្ជាក់ (1) សុពលភាពប្រើប្រាស់របស់លេខ និង (2) អត្តសញ្ញាណរបស់ម្ចាស់លេខ។

ដោយហេតុថាប័ណ្ណជូនដំណឹងនេះអាចបញ្ជាក់បានត្រឹមតែលេខ អ្នកនឹងត្រូវបង្ហាញអត្តសញ្ញាណប័ណ្ណផ្ទាល់ខ្លួនរបស់អ្នក (ឧទា. ប័ណ្ណស្នាក់នៅ លិខិតបញ្ជាក់និវេសនជនអចិន្ត្រៃយ៍ពិសេស)។

### 4. តើប័ណ្ណលេខឯកត្តជន (ប័ណ្ណលេខរបស់ខ្ញុំ) គឺជាអ្វី?

- ប័ណ្ណនេះបញ្ជាក់ទាំងលេខឯកត្តជន និងអត្តសញ្ញាណរបស់អ្នកនៅក្នុងនីតិវិធីទាំងឡាយដែលពាក់ព័ន្ធនឹងលេខឯកត្តជននេះ។ វាក៏ត្រូវប្រើប្រាស់ជាប័ណ្ណសម្គាល់ខ្លួនផ្លូវការរបស់អ្នកផងដែរ។
- អ្នកអាចដាក់ពាក្យសុំប័ណ្ណលេខឯកត្តជនបាន។ មានជម្រើសដាក់ពាក្យជាច្រើនសម្រាប់ឲ្យអ្នកជ្រើសរើសដូចជាបញ្ជូនទម្រង់ពាក្យសុំតាមប្រៃសណីយ៍ (ដែលបានទទួលជាមួយនឹងប័ណ្ណជូនដំណឹងរបស់អ្នក) ដោយភ្ជាប់រូបថតចំពីមុខមកជាមួយ ឬដាក់ពាក្យសុំតាមអ៊ីនធឺណេតដោយប្រើកុំព្យូទ័រ ឬទូរស័ព្ទស្មាតហ្វូន (Smartphone)។ ការចេញប័ណ្ណនេះលើកដំបូងគឺមិនមានគិតប្រាក់កម្រៃនោះទេ។
- បន្ទាប់ពីអ្នកបានដាក់ពាក្យសុំប័ណ្ណលេខឯកត្តជនរួច អ្នកនឹងទទួលបានកាតប៉ុស្តាល់មួយដែលបញ្ជាក់ថាប័ណ្ណ

របស់អ្នកគឺរួចរាល់សម្រាប់ចេញជូន។ អ្នកអាចទៅយកប័ណ្ណរបស់អ្នកនៅការិយាល័យក្រុងដោយយកភ្ជាប់តាមខ្លួននូវ (1) កាតប៉ុស្តាល់នេះ (2) ប័ណ្ណជូនដំណឹងរបស់អ្នក និង (3) អត្តសញ្ញាណប័ណ្ណផ្ទាល់ខ្លួនរបស់អ្នក (ប័ណ្ណស្នាក់នៅ។ល។)។ អ្នកត្រូវកំណត់លេខសម្គាល់ផ្ទាល់ខ្លួនមួយនៅពេលចេញប័ណ្ណនេះ។

- ◆ លេខឯកត្តជនរបស់អ្នកមានសុពលភាពរហូតដល់ខួបលើកទី១០ បន្ទាប់ពីការចេញប័ណ្ណនេះ បើអ្នកមានអាយុចាប់ពី 20ឆ្នាំឡើងទៅ ឬរហូតដល់ខួបលើកទីប្រាំ បើអ្នកមានអាយុក្រោម 20 ឆ្នាំ។ សម្គាល់៖ <u>កាលបរិច្ឆេទផុតសុពលភាពអាចនឹងខុសគ្នាអាស្រ័យទៅតាមរយៈពេលស្នាក់នៅរបស់អ្នក ឬលក្ខខណ្ឌផ្សេងទៀត។</u>
- ◆ ប័ណ្ណនេះមានបង្កប់បន្ទះឈីប IC (IC chip) ដែលអាចផ្ទុកវិញ្ញាបនបត្រអេឡិចត្រូនិចមួយប្រើប្រាស់សម្រាប់ប្រតិវេទន៍ពន្ធតាមអ៊ីនធឺណេត និងសម្រាប់ការអនុវត្តនីតិវិធីផ្សេងៗទៀត។
- ◆ នៅក្រុងមួយចំនួន ប័ណ្ណនេះអាចប្រើប្រាស់សម្រាប់ទទួលសេវាកម្មសាធារណៈនានា (ឧទា.សេវាបណ្ណាល័យសាធារណៈ សេវាចេញវិញ្ញាបនបត្រចុះបញ្ជីត្រាជាដើម) ឬដើម្បីទទួលលិខិតបញ្ជាក់ទីលំនៅរបស់អ្នកជាច្បាប់ចម្លងនៅតាមហាងលក់ទំនិញ។
- ◆ បន្ទះឈីប IC នៅលើប័ណ្ណសម្គាល់លេខឯកត្តជន នឹងមានផ្ទុកឈ្មោះ អាសយដ្ឋានរបស់អ្នក និងព័ត៌មានផ្សេងទៀត ដែលមានសរសេរនៅផ្នែកខាងមុខនៃប័ណ្ណ។ នឹងមិនមានការកត់ត្រាព័ត៌មានសម្ងាត់ផ្ទាល់ខ្លួន ដូចជាប្រាក់ចំណូលរបស់អ្នកនោះទេ។
- ◆ <u>ទោះបីបានទទួលប័ណ្ណលេខឯកត្តជនហើយក្តី អ្នកនៅតែត្រូវបន្តរក្សាទុកប័ណ្ណស្នាក់នៅ លិខិតបញ្ជាក់និវេសនជនអចិន្ត្រៃយ៍ពិសេសរបស់អ្នក។ល។</u>

## 5. បម្រុងប្រយ័ត្នក្នុងការទុកដាក់លេខឯកត្តជន

- ◆ នៅពេលត្រូវការធ្វើបច្ចុប្បន្នភាពអាសយដ្ឋាន ឬព័ត៌មានផ្សេងទៀតនៅលើប័ណ្ណជូនដំណឹង ឬប័ណ្ណលេខឯកត្តជន សូមទាក់ទងទៅកាន់ការិយាល័យក្រុង។
- ◆ មិនមានបុគ្គលណាម្នាក់ត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ ឬប្រមូលប័ណ្ណសម្គាល់លេខឯកត្តជនឡើយ លើកលែងតែច្បាប់អនុញ្ញាត។ បើបុគ្គលណាម្នាក់សុំលេខឯកត្តជនរបស់អ្នក ត្រូវសួរនាំថាតើនរណានឹងប្រើវា ហើយប្រើក្នុងគោលបំណងអ្វី។
- ◆ បុគ្គលណាម្នាក់ដែលទទួលលេខឯកត្តជនរបស់អ្នកដទៃដោយមិនស្របច្បាប់នឹងទទួលការផ្តន្ទាទោស។
- ◆ <u>សូមកុំធ្វេសប្រហែសប្រាប់ពីលេខឯកត្តជនរបស់អ្នកឲ្យអ្នកដទៃបានដឹង ជាពិសេសគឺតាមការហៅទូរស័ព្ទដែលគួរឲ្យសង្ស័យ</u>។

## 6. ការសាកសួរព័ត៌មានទាក់ទងនឹងលេខឯកត្តជន

- ◆ លេខទូរស័ព្ទទាក់ទងដោយឥតគិតថ្លៃ មានជាភាសាអង់គ្លេស ចិន កូរ៉េ អេស្ប៉ាញ និងព័រទុយហ្គាល់
**0120-0178-26 ការសាកសួរព័ត៌មានទាក់ទងនឹងប្រព័ន្ធលេខសន្តិសុខសង្គម និងសារពើពន្ធ**
**0120-0178-27 ការសាកសួរព័ត៌មានទាក់ទងនឹងប័ណ្ណជូនដំណឹង និងប័ណ្ណលេខឯកត្តជន**
ម៉ោង 9:30–20:00 ថ្ងៃធ្វើការ, ម៉ោង 9:30–17:30 ថ្ងៃចុងសប្តាហ៍ និងថ្ងៃឈប់សម្រាកក្នុងឱកាសបុណ្យជាតិ (បិទនៅថ្ងៃឈប់សម្រាកចុងឆ្នាំ/ចូលឆ្នាំថ្មី)។
● ករណីមានការព្យួរជាបន្ទាន់នូវប័ណ្ណលេខឯកត្តជនរបស់អ្នក ដោយសារតែបាត់ ឬចោរលួច សូមទូរស័ព្ទទៅលេខ 0120-0178-27 ដែលមានភ្នាក់ងាររង់ចាំទទួល 24 ម៉ោងពេញមួយសប្តាហ៍ (24/7)។

- ◆ ព័ត៌មានទាក់ទងនឹងលេខឯកត្តជនមានផ្តល់ជូនជាភាសាផ្សេងៗនៅគេហទំព័រដូចខាងក្រោម៖
  - រដ្ឋលេខាធិការដ្ឋានខុទ្ទកាល័យរដ្ឋមន្ត្រី (Cabinet Secretariat): http://www.cas.go.jp/jp/seisaku/bangoseido/
  - J-LIS: https://www.kojinbango-card.go.jp/



គ្រប់គ្នាទទួលបានលេខឯកត្តកជនមួយរៀងៗខ្លួន។ សូមទុកដាក់លេខឯកត្តជនរបស់អ្នកដោយប្រុងប្រយ័ត្ន។